សក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
*****

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ : ២០ សកបយ

ភ្នំពេញ, ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០០

# សេចក្តីជូនដំណឹង

អនុលោមតាមជំពូកទី ១៣ នៃច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា។ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានចេញនូវសារាចរលេខ ០០៥ ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០០ ស្តីអំពីសិទ្ធិ កូដកម្ម របស់កម្មករ និយោជិត។ ការចេញសារាចរនេះ គឺមានបំណងណែនាំអំពីនីតិវិធីនៃការធ្វើកូដកម្មរបស់កម្មករ និយោជិត ដោយជៀសវាងអំពើហិង្សាតែប៉ុណ្ណោះ។ ទន្ទឹមនឹងនេះកន្លងមកក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានទទួលមតិពីសហជីពកម្មករ និយោជិត និងកម្មករនិយោជិត និយោជក និងអង្គការនិយោជក ព្រមទាំងមតិពីសំណាក់អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលបានលើកឡើងនិងធ្វើការបកស្រាយតាមជំហរផ្សេងៗពីគ្នាចំពោះករណីនេះ។

ដើម្បីឆ្លើយតបចំពោះករណីខាងលើនេះក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជូនដំណឹងដូចតទៅ:

១-ទន្ទឹមនិងសិទ្ធិធ្វើកូដកម្មដូចមានចែងក្នុងច្បាប់ស្តីពីការងារ កម្មករ និយោជិត ក៏មានសិទ្ធិធ្វើបាតុកម្ម ដូចពលរដ្ឋទូទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

២-ការកំណត់គុណវឌ្ឍន៍នៃកូដកម្មថាត្រឹមត្រូវតាមច្បាប់ ឬខុសច្បាប់ជាសមត្ថកិច្ចនៃតុលាការ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមអំពាវនាវដល់កម្មករ និយោជិត សហជីពកម្មករ និយោជិត និយោជក និងអង្គការនិយោជក អនុវត្តអោយបានត្រឹមត្រូវនូវសិទ្ធិសេរីភាពទាំងឡាយដែលមានចែងក្នុងច្បាប់។ មធ្យោបាយល្អបំផុតសំរាប់ដោះស្រាយបញ្ហាផ្សេងៗដែលចោទឡើង៍./

មានតែការចរចាជាសមូហភាពដោយសន្តិវិធីតែប៉ុណ្ណោះ។ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នឹងខិតខំប្រឹងប្រែងថែមទៀត ដើម្បី ពង្រឹងការអនុវត្តន៍ច្បាប់ស្តីពីការងារ អោយកាន់តែល្អប្រសើរ ។ល៕

រដ្ឋមន្ត្រី

អ៊ិត សំហេង

ចម្លងជូនៈ
- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន
- សមាគមនិយោជក
- សហព័ន្ធសហជីពកម្មករ និយោជិត
- ស្ថានទូតអាមេរិកប្រចាំកម្ពុជា
- អង្គការអន្តរជាតិខាងការងារ
- ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា
- អង្គការលីកាដូ

"ដើម្បីជូនជ្រាប"

- ឯកសារ-កាលប្បវត្តិ